Reçu le 16-12-50.
INDOCHINE FRANÇAISE RÉGIE DU DÉPÔT LÉGAL

# មិត្តសាលាបាលី

ទស្សនាវដ្ដីផ្សាយព្រះពុទ្ធសាសនា និង អក្សរសាស្ត្រខ្មែរ



ាតិ

Juillet

ឆ្នាំទី ១ កក្កដា លេខ ៧

ព. ស. ២៤៩៣ — គ. ស. ១៩៥០

ទស្សនាវដ្ដីអនុមាសផ្សាយព្រះពុទ្ធសាសនានឹងអក្សរសាស្ត្រខ្មែរ

បណ្ណាធិការ ឈឹម - ក្រសេម

សំណាក់ការលេខ ៣៥ អា., វិថីឧកញ៉ាពេជ្រ ក្រុងភ្នំពេញ

## បញ្ជីរឿង


| | | ទំព័រ |
|---|---|---|
| វិចារណកថា | | ២៤១ |
| កំណត់ហេតុប្រជុំសភាកុងគ្រេស៍នៅលង្កាទ្វីប | | ២៤៣ |
| ប្រវត្តិលោក ជុំ - ម៉ៅ | ជុំ - មួង | ២៥៧ |
| រាត្រីចតុម្មុខ | ញូង - សឿង | ២៦២ |
| ភាសាបាលីនៅប្រទេសកម្ពុជា | មៀវ - ឧត្ត | ២៦៨ |
| បញ្ចតន្ត្រៈ (តមក) សេចក្ដីប្រែរបស់ភិក្ខុ | ប៉ាង - ខាត់ | ២៧៥ |
| សេចក្ដីថ្លែងការណ៍គណកម្មាធិការ | | ២៧៩ |


---


ដំឡៃជាវ

| | |
|---|---|
| ១ ឆ្នាំ | ៩៦,០០ |
| ១ ឆមាស | ៤៨, ០០ |
| ១ ត្រីមាស | ២៤, ០០ |
| ១ ក្បាល | ៨, ០០ |


---

អ្នកអានទាំងឡាយ! សូមអញ្ជើញចុះឈ្មោះជាវ!

នឹងបបួលញាតិមិត្តជួយជាវ!

ជីវិតទស្សនាវដ្ដីស្ថិតលើលោកអ្នក ។

# វិការណកថា

ឧបាទានជាគ្រឿងប្រកាន់មាំនាំឲ្យកាន់ជើងថានេះជាលោកគ្រូយើង នោះជាលោកគ្រូគេ ភ្លេចថាខ្លួនមានជាតដូចគ្នា កាន់ព្រះពុទ្ធសាសនាដូចគ្នា ។

សេចក្តីប្រកាន់នេះ ចាក់ស្រែះស្រគិស្នាញក្រាញស្អឹតក្តាំងនៅក្នុងសន្តានជនណាហើយ, ជននោះរមែងចួបប្រទះនូវសេចក្តីក្តៅក្រហាយទុក្ខទោមនស្សគ្រប់អន្លើ ព្រោះធម៌នេះជាហេតុនាំឲ្យរវាតឃ្លាតពីគ្នា ឲ្យបែកបាក់គ្នា ឲ្យមើលមុខគ្នាមិនត្រង់, ដល់ទៅក្នុងទីបំផុតអាចបញ្ចេញការអន្តរាយរលាយខូចប្រយោជន៍ឥតអំពើមកជាផល ដូចអ្នកជិះទូកឆ្លងទន្លេ មិនគិតនាំគ្នាចំប្រឹងជួយចូកជួយចែវអុំឆ្លងឲ្យបានដល់ត្រើយឆាប់, បែរជាអួតអាងប្រណាំងប្រជែងសំដែងឫទ្ធិដាក់គ្នាថា “ទូកយើងលឿន ទូកអ្នកមិនលឿន ទូកអ្នកមិនល្អ ទូកយើងទើបល្អ” ភ្លេចនាទីរបស់ខ្លួនជាអ្នកឆ្លងដពប ទាល់តែឈ្លោះប្រកាប់ប្រចាក់គ្នា លិចទាំងទូកក្តួលក៏ទាំងអាត្មា ស្លាប់អសារបង់កណ្តាលទន្លេ បានទៅជាចំណីខ្លាមមករទៅ ។

ក្នុងសម័យថ្មីៗនេះ, អ្នកយល់ការជាច្រើនប្រទេស បានចំណាក់បង់បោលនូវឧបាទានដែលជាគ្រឿងអពមង្គលនេះ សំដែងឲ្យយើងឃើញច្បាស់ដោយការលែងប្រកាន់ជាតិត្រកូលពូជពង្ស ហើយបានរួបរួមគ្នាបង្កើតសមាជសម្ពន្ធពុទ្ធសាសនិកពិភពលោក នៅកោះលង្កា មានវត្ត

បំណងដើម្បីផ្សាយពង្រីកពុទ្ធសាសនា ជាទឹកត្រជាក់ត្រជុំឲ្យបានទូលាយទូទៅ នឹងដើម្បីរួបរួមពុទ្ធសាសនិកជនគ្រប់ជាតិគ្រប់សាសន៍ ឲ្យបានមូលមិត្រគ្នា ឲ្យមានមុខឈមទៅរកសន្តិវិធី ដែលជាហេតុនាំឲ្យបន្សាត់បង់បោលនូវសេចក្តីក្តៅក្រហាយពេលពលទុក្ខទោសគ្រប់ជំពូក ។

សមាគមមិត្តសាលាបាលី ក៏មានវត្ថុបំណងស្របគ្នាដូច្នោះដែរ ។ មិត្តសាលាបាលីជាអង្គការមួយនៃពុទ្ធសាសនា ធ្វើការរួបរួមសសោះអនុងប្រមូលមិត្រឲ្យមីរមូលបូលមកអង្គុយរួមតុ:ជាមួយ បណ្តុះបណ្តាលសាមគ្គីធម៌ជាកម្លាំងដើម្បីផ្សាយសាធារណប្រយោជន៍ ។ មិត្តសាលាបាលីត្រូវការរកមិត្រមករួមកំឡាំងជាមួយមិត្រឲ្យមានកាយវាចាចិត្តដូចគ្នា ឲ្យមានចរិយា, សណ្តាប់ធ្នាប់, សីលធម៌, អរិយធម៌និងមេត្តាដូចគ្នា ជាទឹកអប់ស្រោចស្រប់លប់លាងបោលនូវឧបាទាន ។ មិត្តសាលាបាលីមានវត្ថុបំណងតែមួយគឺសាមគ្គីធម៌ ហើយយកខ្លួនជាពលីធ្វើការលើកដំកើងពុទ្ធ-សាសនា ដែលជាសរណវត្ថុដ៏ប្រសើរនិងជាគោលនៃវប្បធម៌និងអរិយ-ធម៌របស់ជាតិ ។ សមាជិកនៃសមាគមមិត្តសាលាបាលីម្នាក់ៗ គប្បីលះបង់ប្រយោជន៍ខ្លួនដោយការបរិច្ចាគធនធាន, ដោយការយកចិត្តទុកដាក់ធ្វៀតយកម៉ោងកំសាន្តរៀងៗខ្លួនមកធ្វើការឲ្យសមាគមដែលជារបស់កណ្តាល ហើយផ្សាយនូវទឹកអម្រឹតដល់ជនរួមជាតិ ។ ការតាំងចិត្តធ្វើដូច្នេះជាកិច្ចបន្សាត់បង់នូវឧបាទានដែលជាគូឧបសគ្គរាំងផ្លូវទៅកាន់សេចក្តីសុខ ទើបឈ្មោះថា សមរម្យទៅតាមវត្ថុបំណងមិត្តសាលាបាលី ។

ម្នាលអានន្ទ! អ្នកណាមួយ ទោះជាភិក្ខុក្តី ជាភិក្ខុនីក្តី ជាឧបាសកក្តី ជាឧបាសិកាក្តី ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែង ប្រព្រឹត្តតាមធម៌, អ្នកនោះទើបឈ្មោះថា ធ្វើសក្ការៈ គោរព រាប់អាន នឹងបូជា ចំពោះតថាគត ដោយការបូជាដ៏ប្រសើរបំផុត ។

មហាបរិនិព្វានសូត្រ មហា. ទីឃ.

# កំណត់ហេតុ

## រឿងប្រជុំសភាកុងគ្រេស

## នៃពុទ្ធសាសនិកសម្ព័ន្ធពិភពលោក

នៅលង្កាទ្វីបពីថ្ងៃទី ២៥ ឧសភាដល់ថ្ងៃទី ៦ មិថុនា ព. ស. ២៤៩៣

គ. ស. ១៩៥០

(បានទទួលពីលោកព្រះគ្រូសង្ឃសត្ថា (ធម្មាភមោ) ប៊ុណ្យ-សុម្ភាជ ជាអ្នករៀបរៀង យកមកចុះផ្សាយក្នុងទស្សនាវដ្តីនេះ)

---

លោកបណ្ឌិត ជ្យ. ប៉. ម៉ៈលាល៉ៈសេកេរៈ (Dr G P. Malalasekera) សាស្ត្រាចារ្យមហាវិទ្យាល័យក្រុងកោលម្បូលង្កាទ្វីប នឹងលោកបណ្ឌិត វ. អឺ. អ. ហ្វុនសេកា (Dr W.E A. Fonseka) បានធ្វើសារលិខិតផ្ញើទៅ អញ្ជើញអ្នកតំណាងគ្រប់ប្រទេស ដែលមានកាន់ព្រះពុទ្ធសាសនា រួម

ការប្រជុំសភាកុងគ្រេស៍ ពុទ្ធសាសនិកសម្ព័ន្ធពិភពលោក (The World fellowship of Buddhists) ។ ប្រទេសដែលបានទទួលអញ្ជើញ ហើយបានចាត់អ្នកតំណាងទៅចូលប្រជុំមាន ២៨ រៀងលេខបញ្ជីតាមលំដាប់អក្សររ៉ូម៉ាំង គឺអង់គ្លេស, អាហ្វ្រិក, អាមេរិក, អូស្ត្រាលី, ភូតាន, ភូមា, កម្ពុជា, លង្កា, ចិន, ហ្វាំងឡង់, បារាំង, អល្លឺម៉ង់, ហុលឡង់, ហាវ៉ៃ, (ឥណ្ឌា, បាគិស្ថាន, សិក្ខិម, អស្សាំ) អ៊ីតាលី, ជប៉ុន, ម៉ាលេស៊ី (គឺសិង្ហបុរីនិងប៉េណាំង) នេប៉ាល, ស្វីស, ស្យេកូស្លូវ៉ាគី, ថៃ, ទីបេត៍ និងវៀតណាម ។

ប្រទេសខ្មែរយើង ពេលនោះបានចាត់និមន្ត សម្តេចព្រះមហាសុមេធាធិបតី (ជោតញ្ញាណោ ជ. ណាត) សង្ឃនាយកគណៈមហានិកាយ, ព្រះគ្រូសង្ឃសត្ថា (ធម្មាភោមា ប៉. សុម្ភាជ) សាស្ត្រាចារ្យសំស្ក្រឹតសាលាបាលីជាន់ខ្ពស់ និងលោកអ្នកឧកញ៉ាប្រាក់-សារិន្ទ អគ្គលេខាធិការក្រសួងការបរទេស ជាប្រតិភូ ។ ឧកញ៉ាកេត្យាសម្បត្តិ គាន់-បូហេង និងគហបតី ប៉េ.យ៉ាន ក៏បានទៅជាមួយផងដែរ ក្នុងឋានៈជាឧបាសកវេយ្យាវច្ចករ ។

ពួកគណៈប្រតិភូប្រទេសនានា សព្វទិសាភាគនៃភូគោលនេះ បានទៅដល់លង្កាទ្វីបហើយ បានទទួលសេចក្តីទំនុកបម្រុងក្នុងការសំណាក់អាស្រ័យ ក្នុងវត្តអារាមនិងលំនៅនៃពុទ្ធសាសនិកជន យ៉ាងស្មោះសរ ជាទីគួរឲ្យរលឹកនឹកចាំបានក្នុងសន្តានចិត្ត ឥតមានភ្លេចគ្រប់គ្នា ។

នៅថ្ងៃទី ២៤ ឧសភា ពួកប្រតិភូទៅកាន់ក្រុងក័ណ្ឌី (Kandy) ដែលជារាជធានីអំពីបុរាណ ប្រជុំគ្នាធ្វើពិធីសម្ពោធបើកសម័យប្រជុំ នៅក្នុងមន្ទីរតម្កល់ព្រះចង្កូមកែវ ក្រោមអធិបតីភាពនៃព្រះនាយកមហាថេរ មល្វត្តេនិងអស្សគិរី ។ លោកបណ្ឌិត ម៉ៈល៉ាល៉ៈសេកេរៈជាអ្នកថ្លែងបើកឧកាសប្រជុំសភាក្នុងគ្រេស៍ ។ លំដាប់មកមានការថ្លែងសុន្ទរកថាជាច្រើន ។

តពីនោះមក ពួកឧបាសិកានៃពុទ្ធិកសមាគមក្រុងក័ណ្ឌី រៀបទទួលលៀងភោជនាហារ រួចហើយពួកប្រតិភូបាននាំគ្នាត្រឡប់មកកាន់ក្រុងកោលម្បូវិញ ។

ថ្ងៃទី ២៦ ឧសភា ម៉ោង ១៧ ប្រជុំគ្នានៅកីឡដ្ឋានប្រណាំងសេះក្រុងកោលម្បូ ។ ភិក្ខុសង្ឃជាច្រើនរយរូប គង់លើវេទិកាចំរើនព្រះបរិត្តនៅជុំវិញព្រះពុទ្ធរូបអង្គធំមួយព្រះអង្គ ។ ក្រោយមកមានស័ព្ទភ្លេងត្រែស័ង្ខបន្លឺឡើងក្នុងកណ្តាលទីប្រជុំជនរាប់ម៉ឺននាក់ ។ មហាជនទទួលបញ្ចសីល, នាយកគណៈប្រតិភូថ្លែងសុន្ទរកថា និងសារលិខិត ។

ថ្ងៃទី ២៧-២៨-២៩ ឧសភា មានការប្រជុំនៅមហាសភាទាំងព្រឹកទាំងល្ងាច ។ ពួកប្រតិភូថ្លែងសេចក្តីអំពីប្រវត្តិការណ៍ព្រះពុទ្ធសាសនានៅប្រទេសរបស់ខ្លួនម្នាក់ម្តងៗ តាមលំដាប់វេន ហើយទើបដំនុំសម្រេចសេចក្តីទៅតាមរបៀបការៈ ។

ខ្ញុំសូមស្រង់សេចក្ដី ដែលសម្ដេចព្រះមហាសុមេធាធិបតី សង្ឃ-នាយកគណៈមហានិកាយជានាយកគណៈប្រតិភូប្រទេសកម្ពុជាយើង បានថ្លែងជាភាសាបាលី ដោយព្រះឱស្ឋទេ ដូចមានសេចក្ដីតទៅនេះ

អស់លោកអ្នកប្រតិភូដ៏បវរទាំងឡាយ,

លោកអ្នកពលគ្នាប្រហែលជាពុំបានស្គាល់ប្រទេសកម្ពុជា ដោយជាក់លាក់ទេ? ព្រោះជាប្រទេសតូច កំបាំងបាត់ក្នុងផែនទីលោក, វៀរតែលោកអ្នកខ្លះ ដែលបានអញ្ជើញទៅមើលប្រាសាទនគរវត្ត នោះទើបបានស្គាល់ប្រទេសកម្ពុជាដោយជាក់លាក់ ។ កម្ពុជរដ្ឋជាប្រទេសមួយដែលមានកាន់សាសនាតែមួយបែប គឺព្រះពុទ្ធសាសនា, ប្រជាជនជាតិខ្មែរ ទោះបីជាអ្នកប្រព្រឹត្តអំពើឆ្គាំឆ្គងខ្លះ ក៏គង់តែចូលទៅកាន់វត្តអារាមដោយកាលដោយសម័យ ប្រកាសខ្លួនថាជាអ្នកកាន់ព្រះពុទ្ធ-សាសនាដែរ ។ ជនជាតិខ្មែរដែលបែកបែរចិត្តគំនិតទៅកាន់សាសនាដទៃមានតិចណាស់ ប្រហែលជាមួយរយនាក់ប៉ុណ្ណោះ ហើយមានតែនៅទីក្រុងធំទេ ។

អង្គព្រះមហាក្សត្រិយ៍របស់យើងសព្វថ្ងៃនេះ ជាព្រះពុទ្ធសាស-នូបត្ថម្ភក៍ពេញទី ទ្រង់បានលះបង់រាជសម្បត្តិបំពេញព្រះផ្នួសជាភិក្ខុភាវអស់មួយវស្សាហើយ ទើបទ្រង់លាសិក្ខាត្រឡប់ទៅទទួលសោយរាជ-សម្បត្តិវិញ ។

តាមប្រវត្តិសាស្ត្រ ថាក្នុងរវាងសតវត្សរ៍ទី ១៧ នៃ ព.ស (ទី ១២ នៃ គ.ស.) មានព្រះពុទ្ធសាសនាប៉ែកខាងឧត្តរនិកាយ (អាចរិយវាទ ឬមហាយាន) ចូលមកប្រទេសខ្មែរ មុនដំបូង, លុះដល់មកសតវត្សរ៍ទី ២០ នៃ ព.ស. (ទី ១៥ នៃ គ.ស.) ទើបមានព្រះពុទ្ធសាសនាប៉ែកខាងទក្ខិណនិកាយ (ថេរវាទឬហីនយាន) ចូលមក ហើយក៏ចេះតែបានលូតលាស់ចំរើនជាលំដាប់ ដរាបដល់សព្វថ្ងៃនេះ មានវត្តចំនួន ២.៦៥៦ មានព្រះភិក្ខុសង្ឃចំនួនប្រហែល ៣៧.៥៥៣ រូប ។

## អំពីគន្ថធុរៈ

អង្គការដែលនាំឲ្យព្រះពុទ្ធសាសនាបានរីកចំរើនទូលំទូលាយនោះគឺ:

តាំងពីក្នុងខាងចុងសតវត្សរ៍ ទី ២៤ នៃ ព.ស (ខាងដើមសតវត្សរ៍ទី ១៩ នៃ គ.ស.) ពីក្នុងរជ្ជកាលព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី (ព្រះអង្គដួង) រៀងមក ព្រះពុទ្ធសាសនាមានសេចក្តីចំរើនបន្តិចៗ តាមលំដាប់មក ។ ដល់មកខាងដើមសតវត្សរ៍ទី ២៥ នៃ ព.ស. (ចុងសតវត្សរ៍ទី ១៩ នៃ គ.ស.) ក្នុងរជ្ជកាលព្រះបាទសម្តេចព្រះនរោត្តម មានពិធីដេញប្រយោគប្រែបាលីកំណត់ត្រឹមប្រយោគ ៥ ។ តមក ព.ស. ២៤៥២ គ.ស ១៩០៩ មានបង្កើតសាលាបាលីនៅនគរវត្ត បានត្រឹមតែ ៣ ឆ្នាំ ។ ដល់មក ព.ស. ២៤៥៥ គ.ស. ១៩១២ ក្នុងរជ្ជកាលព្រះបាទសម្តេចព្រះសិរីសុវត្ថិ មានពិធីដេញប្រយោគម្តងទៀត នៅទីវិហារ

ព្រះកៃវមរេគតកំណត់ត្រឹមតែប្រយោគ ៤ ។ ដល់មក ព. ស. ២៤៥៧ គ. ស ១៩១៤ មានបង្កើតសាលាបាលីជាន់ខ្ពស់ នៅក្រុងភ្នំពេញ ជាជំនួសសាលាបាលីដែលតាំងនៅនគរវត្ត ។ ដរាបមកដល់ឥឡូវនេះ ចំនួន ៣៦ ឆ្នាំហើយ សិស្សដែលបានប្រឡងជាប់ចេញពីសាលានេះ មានចំនួន ៧៦២ រូបហើយ នៅទ្រទ្រង់ភេទជាបព្វជិតខ្លះ សឹកទៅជាគ្រហស្ថខ្លះ ។ សព្វថ្ងៃ មានសិស្សនៅរៀនជាង ២០០ រូបរាល់ឆ្នាំ ។

ព. ស. ២៤៦៨ គ. ស. ១៩២៥ បានបើកព្រះរាជបណ្ណាល័យកម្ពុជា ។

ព. ស. ២៤៧៣ គ. ស. ១៩៣០ បានបង្កើតឲ្យមានពុទ្ធសាសនបណ្ឌិត្យ ។

ព. ស ២៤៧៤ គ ស. ១៩៣១ បានបោះពុម្ពព្រះត្រៃបិដកប្រែជាភាសាខ្មែរ បានគ្រោងទុកថានឹងបោះពុម្ពដរាបដល់ចប់ មានចំនួន ១១០ ភាគ បានប្រែហើយស្រេច តែឥឡូវនេះទើបនឹងបោះពុម្ពបានចំនួន ៣៥ ភាគ សព្វថ្ងៃនេះបានចាប់ការបោះពុម្ពពីភាគទី ៣៦ តទៅទៀតហើយ ។

ព. ស. ២៤៧៦ គ. ស. ១៩៣៣ បានបង្កើតឲ្យមានសាលាបាលីរងនៅក្នុងក្រុងខ្លះ នៅខេត្តក្រៅខ្លះ ដរាបមកដល់ឥឡូវនេះ បាន ១៧ ឆ្នាំហើយ មានសាលាចំនួន ២៤៨ មានសិស្សប្រឡងចេញ រួបរួមទាំងអស់ក្នុងមួយឆ្នាំៗ ជាង ១.០០០ រូប ។

ព. ស. ២៤៨៧ គ ស. ១៩៤៤ មានព្រះរាជក្រមបញ្ញត្តិឲ្យភិក្ខុសាមណេរប្រើប្រាស់ចីវរតែបែបមួយតាមព្រះវិន័យ ឲ្យសាមណេរឃុំចីវរ

ចូលភូមិជាដើម ដើម្បីឲ្យភិក្ខុសាមណេរ មានរបៀបរបបដូចគ្នា ប្រតិបត្តិត្រឹមត្រង់តាមព្រះវិន័យបិដក ។

## អំពីវិបស្សនាធុរៈ (ធុរៈខាងផ្លូវចិត្ត)

ធុរៈនេះ ភិក្ខុសាមណេរទាំងគ្រហស្ថ តែងប្រតិបត្តិជាប់មកជាយូរអង្វែងហើយ ប៉ុន្តែពុំទាន់បានរៀបចំឲ្យមានរបៀបរបបដោយត្រឹមត្រូវនៅឡើយ ។ បានបំរុងនឹងរៀបចំផ្លូវប្រតិបត្តិខាងវិបស្សនាធុរៈ ក្នុងឆ្នាំតទៅមុខ, កាលបើមានឱកាសល្មមធ្វើទៅបាន, នឹងរៀបចំឲ្យបានត្រឹមត្រូវ នឹងមិនបណ្តោយឲ្យពុទ្ធសាសនិកជន ប្រតិបត្តិខុសចាកគន្លងច្បាប់ឡើយ ព្រោះធុរៈនេះ ជាធុរៈខាងផ្លូវចិត្ត បើបណ្តែតបណ្តោយទៅនឹងនាំឲ្យខូចខាងផ្លូវចិត្ត ខូចសតិបញ្ញា ។ ហេតុនេះ យើងបានបម្រុងនឹងរៀបចំក្រុមអ្នកប្រាជ្ញមួយក្រុម ឲ្យជាអ្នកពិនិត្យចំណេះវិជ្ជាបព្វជិតឬគ្រហស្ថដែលជាអាចារ្យបង្រៀន ។ បើឃើញថាមានចំណេះវិជ្ជាត្រឹមត្រង់តាមគម្ពីរវិសុទ្ធិមគ្គហើយ ទើបអនុញ្ញាតឲ្យមានអំណាចបង្ហាត់បង្រៀនឬពន្យល់ក្នុងផ្លូវវិបស្សនាធុរៈដល់ពុទ្ធសាសនិកជនតទៅទៀតបាន ។

## អំពីការទំនុកបម្រុងព្រះពុទ្ធសាសនា

នៅប្រទេសខ្មែរ មានបង្កើតពុទ្ធិកសមាគមម្តង ។

កាលពីឆ្នាំមុននេះ (ព.ស. ២៤៩២ គ.ស. ១៩៤៩) មានបង្កើតសមាគមខាងព្រះពុទ្ធសាសនា ២ គឺ:

១ – សមាគមមិត្តសាលាបាលី ជាជំនួសពុទ្ធិកសមាគម ដើម្បីៈ

ក – ប្រមូលសិស្សានុសិស្សនិងមិត្តទាំងឡាយនៃសាលាបាលី ដែលមានបំណងនឹងលើកដំកើងភាសានិងអក្សរជាតិ ។

ខ – ឧបត្ថម្ភអ្នកសិក្សាភាសាបាលីនិងភាសាជាតិ ដោយសម្ភារៈនិងសីលធម៌ ។

គ – បង្កើតឲ្យមានការបោះពុម្ពទស្សនាវដ្តីឬសារពត៌មាន និងសៀវភៅផ្សេងៗ ដើម្បីពង្រីកអក្សរសាស្ត្រខ្មែរ ។

ឃ – បង្កើតឲ្យមានបណ្ណាល័យសម្រាប់សមាគម ។

ង – សង្គ្រោះដល់អ្នកមានប្រាជ្ញាវាងវៃដែលចេញទៅសិក្សាឯប្រទេសក្រៅ ។

២ – សមាគមគិលានសង្គ្រោះចំពោះព្រះសង្ឃខ្មែរ ដើម្បីជួយព្យាបាលព្រះសង្ឃខ្មែរដែលមានអាពាធ ។

## អំពីការគ្រប់គ្រងព្រះពុទ្ធសាសនា

ដោយហេតុព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ, ព្រះករុណាជាម្ចាស់ជីវិត ទ្រង់ជាអគ្គសាសនូបត្ថម្ភក៍ ទ្រង់បានចាត់តាំងឲ្យមានក្រសួងធម្មការ ទ្រង់បានតែងតាំងព្រះសង្ឃនាយក និងព្រះរាជាគណៈឋានានុក្រមនិងមន្ត្រីសង្ឃគណស្រុក - ខេត្ត មេគណ អនុគណ ជាប្រមុខ

នឹងទៅអធិការ ត្រួតត្រា ក្នុងក្រុងនឹងខែត្រក្រៅ ដើម្បីគ្រប់គ្រងសង្ឃមណ្ឌលឲ្យបានសេចក្ដីចំរើនដរាបមក ។

## កិច្ចការដែលបម្រុងនឹងធ្វើតទៅអនាគត

សព្វថ្ងៃនេះ កំពុងរៀបចំបង្កើតឲ្យមានសាលាធម្មវិន័យរាល់វត្តសម្រាប់ភិក្ខុសាមណេរដែលទើបនឹងបួស, ដែលពុំបានរៀនភាសាបាលីឬក៏បានរៀនភាសាបាលីដែរហើយ ប៉ុន្តែចង់ឲ្យបានចេះជ្រៅជ្រះក្នុងធម៌និងវិន័យថែមទៀត ។ ប្រហែល ២ ឬ ៣ខែទៀត ការរៀបចំនេះនឹងបានសម្រេច ។ សាលារៀនធម្មវិន័យនេះ មានអនុញ្ញាតជាបណ្ដោះអាសន្ន ឲ្យរៀនខ្លះហើយ ។

## គោបត្តិ បុតិបត្តិ

នៅប្រទេសខ្មែរ ភិក្ខុសាមណេរតែងធ្វើវត្តប្រតិបត្តិតាមលំអានព្រះធម៌វិន័យគោរពនមស្ការចំពោះព្រះរតនត្រ័យព្រឹកល្ងាច សូត្រធម៌ផ្សាយមេត្តាចំពោះលោកទាំងមូលរាល់ថ្ងៃ ។ យើងសង្ឃឹមថា បើលោកទាំងមូលនេះ បានសេចក្ដីសុខស្ងប់ ព្រះពុទ្ធសាសនាក្នុងប្រទេសយើងនឹងមានសេចក្ដីរុងរឿង អាចជាជំនួយដល់អ្នកប្រតិបត្តិព្រះពុទ្ធសាសនាគ្រប់ប្រទេសក្នុងលោកបានខ្លះ ប៉ុន្តែការផ្សាយព្រះពុទ្ធសាសនារបស់យើង គឺផ្សាយដោយស្ងប់ស្ងៀម ប្រទេសនានាក្នុងលោកស្ទើរតែពុំ

បានដឹងឮផង, ទាំងនេះ មិនមែនជាយើងរួញគំនិតប្កុំណាញ់ព្រះពុទ្ធសាសនាទេ គឺយើងធ្វើទៅតាមការណ៍សមនឹងកម្លាំងរបស់ប្រទេស ។

នៅពេលដែលគណៈប្រតិភូខ្មែរ រៀបចេញដំណើរត្រឡប់ពីលង្កាទ្វីបមកវិញ មហាវិទ្យាល័យនៃប្រទេសនេះបានសុំសារលិខិតមួយច្បាប់ ដើម្បីនឹងយកទៅបោះពុម្ពទស្សនាវដ្ដីផ្សាយ សម្ដេចព្រះមហាសុមេធាធិបតី បានឆ្លើយទៅទកថា ជាភាសាបាលីថា: "តយោ វារេ លង្កាទីបមាគតោ អម្ហាកំ សម្មាសម្ពុទ្ធោ ។ល។ តំ តត្ថ តេសំ តុរិតំ សមិជ្ឈតុ" ។

## សេចក្ដីប្រែ

យើងធ្លាប់បានដឹងមកហើយថា ព្រះបរមសម្មាសម្ពុទ្ធរបស់យើងបានទ្រង់ស្ដេចមកកាន់លង្កាទ្វីប អស់វារៈ ៣ ដង, លុះព្រះអង្គទ្រង់បរិនិព្វានទៅ ក្នុងសតវត្សរ៍ទី ៣ នៃ ព.ស. ក្នុងរជ្ជកាល នៃព្រះមហារាជព្រះនាមទេវានម្បិយតិស្ស, ព្រះមហិន្ទត្ថេរបាននាំព្រះពុទ្ធសាសនាមកប្រតិស្ឋាននៅលង្កាទ្វីប; ចាប់តាំងពីពេលនោះមក ព្រះពុទ្ធសាសនាក្នុងលង្កាទ្វីបក៏បានចំរើនរុងរឿងដោយក្រៃលែង ប៉ុន្តែយើងមិនធ្លាប់ដែលបានមកឃើញលង្កាទ្វីបសោះ ទើបតែក្នុងពេលនេះ ដោយសារសេចក្ដីនិមន្តអញ្ជើញនៃពុទ្ធមាមកជនអ្នកលង្កាទ្វីប មានលោកបណ្ឌិតម៉ៈឡ៉ាល៉ៈសេកេរៈជាដើម យើងបានមកដល់លង្កាទ្វីបនេះជាដំបូងបង្អស់ ដើម្បីមក

ប្រជុំមហាសន្និបាតក្នុងពុទ្ធិកសមាគម ។ យើងបានមកឃើញប្រត្យក្សនឹង
ភ្នែកនូវបូជនីយដ្ឋានជាច្រើនកន្លែង, សុទ្ធសឹងជាទីមនោរម្យនាំឲ្យរីករាយ
ជ្រះថ្លាជាបំផុត ។ ទាំងព្រះមហាធាតុ (ព្រះចង្កូមកែវ) ខាងក្រោម
ខាងស្តាំនៃព្រះដ៏មានព្រះភាគ ក៏យើងបានឃើញហើយ. គ្រាន់តែឃើញ
ភ្លាម ក៏កើតចិត្តជ្រះថ្លាក្រៃលែង; ក្នុងពេលថ្វាយបង្គំ យើងមិនអាចទប់ទល់
ផលទៀតបាន ព្រោះមិនធ្លាប់បានឃើញសោះ យើងយល់ជាក់ប្រាកដថា
បានបុណ្យានិសង្សដ៏ធំក្រៃលែង យើងសូមតាំងសច្ចាធិដ្ឋានថា:

ដោយអំណាចបុញ្ញតេជៈនេះ សូមជនានុជនគ្រប់ប្រទេស

បានដល់នូវសេចក្តីចំរើនល្អលាស់ និងសន្តិភាពកុំបីឃ្លាតឡើយ ។

យើងបានមកឃើញបាឋសាលានានា និងបរិវេណសាលាសម្រាប់
បព្វជិតជាច្រើនក្នុងលង្កាទ្វីបនេះ, លុះឃើញហើយ យើងកើតមាន
យោបល់យល់ថា សីហឡទ្វីបនេះ បរិបូណ៌ដោយ ពុទ្ធសាសនសិក្សា,
វិជ្ជាសិក្សា, ចរិយាសិក្សា, កម្មករណសិក្សា, និងកាយបរិហារសិក្សា;
អ្នកលង្កាទ្វីបជាអ្នកប្រកបដោយសីលធម៌ គួរយកតម្រាប់តាម; ពុទ្ធមា-
មកជនអ្នកមានសទ្ធានិងសីលក៏មានច្រើន ។ ចាប់តាំងពីពេលនេះទៅ
កម្ពុជរដ្ឋគួរតែចងសម្ព័ន្ធមេត្រីយ៉ាងជិតស្និទ្ធ ខាងព្រះពុទ្ធសាសនាជាមួយ
នឹងកោះលង្កានេះ ហើយត្រូវបញ្ជូនបព្វជិតជាតិខ្មែរមកសិក្សាក្នុងសាលា
ពុទ្ធសាសនបរិវេណនៅលង្កាទ្វីបនេះ ជាលំដាប់, ទាំងបព្វជិតជាតិលង្កា

ក៏គួរបញ្ជូនទៅកម្ពុជរដ្ឋវិញដូចគ្នាក៏បានដែរ ។ កាលបើយ៉ាងនេះព្រះពុទ្ធ-សាសនានឹងបានរីកទូលំទូលាយ ផ្សាយទៅក្នុងលោកទាំងមូលយ៉ាងរុងរោចន៍, ពិភពលោកក៏ប្រហែលជានឹងបានសន្តិសុខដោយសារពុទ្ធសា-សនានុភាពពុំខាន ។ .

ម្យ៉ាងទៀត យើងជាបព្វជិតទាំងពីររូបគឺខ្ញុំនឹងឆ្មាភមភិក្ខុជាអន្តេវា-សិករបស់ខ្ញុំ បានមកសំណាក់អាស្រ័យនៅក្នុងវត្តផិកកាម អស់កាលជាងកន្លះខែ ដោយសេចក្ដីសុខស្រួលសព្វអន្លើ ទាំងឧបាសកបីនាក់ដែលសំណាក់អាស្រ័យក្នុងលំនៅនៃពុទ្ធមាមកជនជាសប្បុរស ក៏បានសេចក្ដីសុខស្រួលដូចគ្នា ។

កាលបើយើងត្រឡប់ពីនេះ ទៅដល់កម្ពុជរដ្ឋវិញ យើងនឹងពណ៌-នាតែអំពីអំពើល្អនឹងសម្មាប្រតិបត្តិណាដែលល្អប្រពៃជាងជនជាតិយើងក្នុងទីមហាសន្និបាត; ព្រោះហេតុអ្វី? ព្រោះយើងប្រាថ្នាតែសេចក្ដីចំរើនលូតលាស់ម្យ៉ាង ចំពោះប្រទេសជាតិរបស់យើង ។

(ក្នុងទីបំផុត មានគាថាជាត់ទន្វំសប្ពន្នចែងសព្វសាធុការម្ដងទៀតចំពោះអ្នកលង្កាទ្វីបថា:)

លង្កាធិកាសី សុខិតា ច ធិក្កយា
ពុទ្ធស្ស ធម្ម បិតកា ច យោទ្ធា តេ
យំ យញ្ញា ឥច្ឆន្តិ យទិច្ឆិតំ សទា
តំ តញ្ច តេសំ តុវិតំ សមិជ្ឈតុ!

សូមឲ្យអ្នកលង្កាទាំងឡាយនោះ មានសេចក្ដីសុខ ប្រាសចាកទុក្ខភ័យ ស្ថិតនៅក្នុងធម្មវិន័យរបស់ព្រះសម្មាសម្ពុទ្ធ; ម្យ៉ាងទៀត អ្នកលង្កាប្រាថ្នាយ៉ាងណា ៗ សូមឲ្យបានសម្រេចដល់អ្នកទាំងនោះ សមគួរតាមសេចក្ដីប្រាថ្នាយ៉ាងនោះៗ ឲ្យបានធាប់របស់សព្វកាលតរៀងទៅ ៗ

មិនត្រឹមតែប៉ុណ្ណោះឡើយ, សម្ដេចព្រះមហាសុមេធាធិបតី ជានាយកគណៈប្រតិភូខ្មែរ បានផ្ញើលិខិតជាភាសាបារាំងមួយច្បាប់ថ្លែងអំណរចំពោះ សមាគម "មិត្តព្រះពុទ្ធសាសនា" (Société des Amis du Bouddhisme) ជូនអ្នកកញ្ញា ឈ្មោះ ឡូន-ស្បេរី (Mlle Lounsbery) ប្រធាន-ការនៃសមាគមនោះ សឹងមានចុះក្នុងទស្សនាវដ្ដី "ពុទ្ធចិន្ដា" (La Pensée Bouddhique) លេខ ២ នៃភាគទី ៣ សម្រាប់ខែកក្កដា គ. ស. ១៩៥០ ស្រាប់ មានសេចក្ដីថា:

គណៈប្រតិភូខ្មែរ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសមាគម "មិត្តព្រះពុទ្ធសាសនា" ដោយហេតុដែលបានផ្ញើចុតហ្មាយថ្វាយព្រះករុណាជាម្ចាស់ជីវិតរបស់យើង សូមព្រះបរមរាជានុញ្ញាតចាត់តាំងគណៈបេសកកម្មមួយដើម្បីជាតំណាងប្រទេសកម្ពុជា ក្នុងឱកាសប្រជុំសភាកុងគ្រេស៍ ពុទ្ធសាសនិកសម្ពន្ធពិភពលោកនៅលង្កាទ្វីប ៗ

កម្ពុជរដ្ឋអាចបានទទួលឋានៈ របស់ខ្លួនក្នុងមជ្ឈដ្ឋាននៃប្រទេសនានាដែលកាន់ព្រះពុទ្ធសាសនា ៗ ការទាក់ទងដែលយើងបានធ្វើក្នុងទីប្រជុំ

នៃប្រជាជាតិ ដ៏ច្រើន យ៉ាងនេះគង់នឹងឲ្យកើតផលដ៏ប្រសើរចំពោះកម្ពុជរដ្ឋ ពុំខាន ។ យើងសង្ឃឹមថាតទៅអនាគត នឹងមានឱកាសល្អ យ៉ាងនេះទៀត ហើយសង្ឃឹមថាសិស្សទាំងឡាយរបស់យើងនឹងអាចបានទៅកាន់ប្រទេសដទៃដែលកាន់ព្រះពុទ្ធសាសនាដូចគ្នា ដើម្បីសិក្សាភាសាដទៃក្រៅពីបាលីដែលយើងមានគ្រប់គ្រាន់ហើយក្នុងសម័យបច្ចុប្បន្ននេះ ។

ដោយសារតែសមាគម "មិត្តព្រះពុទ្ធសាសនា" នឹងលោកបណ្ឌិត ម៉ាឡាលះសេកេរៈ, គណៈប្រតិភូខ្មែរបានឱកាសធ្វើការកិច្ចចំពោះបូជនីយដ្ឋានទាំងឡាយនៅលង្កាទ្វីប ចាត់ថាជាអនុស្សរណៈ របស់យើងមួយដែលនៅចាំជាក់ក្នុងចិត្តតតគ្រប់សោះ ។

ក្នុងទីនេះ យើងសូមអ្នកកញ្ញាប្រធានិកាទទួលនូវមនោសញ្ចេតនានៃអំណរគុណ យ៉ាងជ្រាលជ្រៅរបស់យើង ។

ការប្រជុំសភាក្នុងគ្រេស់នេះ បានសម្រេចផល យ៉ាងណាៗ នឹងមានស្រង់ចេញពីសេចក្ដីគត់ហេតុដែលគណៈកម្មាធិការនាយកនឹងផ្ញើមកឲ្យ នឹងចុះក្នុងសៀវភៅដែលកំពុងតែងបម្រុងនឹងបោះពុម្ព ក្នុងពេលខាងមុខនេះ ។

# អក្សរសាស្ត្រជាពន្លឺជាតិ ជាគោលហរិកជាតិ
# អក្សរសាស្ត្ររលត់ ជាតិរលត់ ។

## ប្រវត្តិលោក ជុំ-ម៉ៅ ហៅ ជុំ-ម៉ូ

លោកជុំ-ម៉ៅ កើតឆ្នាំជូត ថ្ងៃព្រហស្បតិ៍ ខែអាសាឍ ព.ស. ២៤៤៣ (គ.ស ១៩០០) នៅភូមិកំពង់សៀម, ឃុំកំពង់សៀម, ខេត្តកំពង់សៀមប៉ែកឆ្វេង (ឥឡូវទៅជាភូមិកំពង់សៀម, ឃុំសំពេង, ស្រុកព្រៃឈរ ទីរួមខេត្តកំពង់ចាម) ។ បិតានាមជុំ, ជាអាចារ្យវត្តកំពង់សៀម ដែលកាលពីកជ្យព្រះករុណាសុវណ្ណគោដ្ឋធ្វើជាស្មៀនអាជ្ញាលួង ។ មាតានាមនៅ ។ លោកមានភរិយាឈ្មោះអ្នកស្រីផុន, មានបុត្រាបុត្រី ១២ នាក់ (ស្លាប់ ៥ នាក់, នៅសព្វថ្ងៃនេះ ៧ នាក់) ។

កាលពីបឋមវ័យ កុមារជុំ-ម៉ៅ បានសិក្សាអក្សរជាតិដោយឆាប់រហ័សក្នុងសំណាក់បិតានៅផ្ទះរបស់ខ្លួនទាល់តែចេះមុតមាំ ទើបទៅនៅវត្តកំពង់សៀមក្នុងសំណាក់លោកគ្រូចៅអធិការ ពេជ្រ គ្រាន់តែបង្គ្រប់ការតាមទំនៀមស្រុក ។ កុមារ ជុំ-ម៉ៅ បានទៅសិក្សាភាសាបាលីជាមួយសាមណេរ ជុំ-កៅ ជាបងនៅវត្តបន្ទាយថ្មី ជិតឃុំកំពង់សៀម ក្នុងសំណាក់អាចារ្យប្រែស កេទគ្រហស្ថ ។ ប៉ុន្តែអាចារ្យប្រែសចេះតែយកដើរតាមទៅទីផ្សេងៗ នាំឲ្យរំខានដល់ការសិក្សា មិនបានរៀនសូត្រ

ពេញលេញដូចបង, មិនយូរប៉ុន្មានក៏ត្រឡប់ជាឈប់រៀនភាសាបាលីនោះទៅវិញ ។ ក្នុងអាយុ ១១ ឬ ១២ឆ្នាំ ដោយប៉ិនប្រសប់ខាងវិជ្ជាអក្សរខ្មែរមុតមាំទាំងល្អទាំងរហ័ស, កុមារជុំ-មៅ ក៏បានធ្វើស្មៀនមេឃុំ ២ឃុំ គឺឃុំសិនសុន និងឃុំខ្វា, (ស្រុកព្រៃឈរ ខេត្តកំពង់ចាម) ។

កាល គ.ស. ១៩១២ លោកគ្រូព្រះពុទ្ធវង្ស (ម៉ី) កាលគង់ព្រះជន្មនៅឡើយ, ធ្វើជាអ្នកដើរត្រួតត្រាផ្សាយអក្សរខ្មែរក្នុងខេត្តផ្សេង ៗ បានទៅប្រជុំនៅសាលាគណ ពាមក្នុងខេត្តកំពង់ចាម ដើម្បីពន្យល់ពីការកែប្រែអក្សរខ្មែរតាមរបៀបថ្មី ព្រោះក្នុងសម័យនោះគេនៅរាប់ថា ក កា កិ (កឹក) កី កុ (កុក) កូ (កូវ) ។ល។ នៅឡើយ ហើយគ្មានប្រើស្រៈ អឹ, អឺ និង អឿ ទេ; ពាក្យថាក្បឿង គេសរសេរថាក្បៀង ។ ជាន់នោះនៅវត្តកំពង់សៀម ឥតអ្នកណាប៉ិនខាងអក្សរខ្មែរ គេក៏បានបាត់កុមារ ជុំ-មៅ ឲ្យទៅជំនុំគណាងវត្តនោះ ។

ដល់អាយុ ១៣ ឆ្នាំ, កុមារ ជុំ-មៅ បានមកសិក្សាអក្សរភាសាបារាំងសែសឯក្រុងភ្នំពេញ ហើយបានប្រឡងជាប់បដិញ្ញាណបឋមសិក្សាបារាំង-ខ្មែរក្នុងអាយុ ១៩ ឆ្នាំ ។ ក្រោយដែលបានចូលរៀននៅអនុ-វិទ្យាល័យស៊ីសុវត្ថិ (ចាស់) បាន ១ ឆ្នាំ កុមារ ជុំ-មៅ ក៏ឈប់រៀន រួចបានមកប្រឡងចូលរៀនសាលាច្បាប់ជាមួយអ្នកអង្គម្ចាស់ សិង្ហរា ក្នុងឆ្នាំ ១៩១៩ ហើយប្រឡងចេញពីសាលាក្នុងឆ្នាំ ១៩២១ ក៏ត្រូវបាត់ឲ្យទៅ

ធ្វើជាស្មៀន មុនដំបូងបង្អស់នៅស្រុកមូលប៉ាមោក (រ៉ុនសៃ) ក្នុងខែត្រ ស្ទឹងត្រែងចំនួន ៣ ឆ្នាំ ហើយបានឡើងជាយោក្រប័ត្រ ។ កាលនៅ រ៉ុនសៃ, យោក្រប័ត្រ ជុំ-ម៉ៅ បានរៀនអក្សរ-ភាសាលាវចេះមុតមាំ ព្រម ទាំងបានទទួលធ្វើជាគ្រូបង្រៀនអក្សរលាវ ដល់កុមារជាតិលាវនៅទីនោះ ផងទៀត ហើយបានតែងសៀវភៅបទានុក្រមបារាំង-លាវជូនដេឡេគេ នៅដំបន់នោះមួយសៀវភៅផង, មានសេចក្ដីសរសើរជាច្រើនពីដេឡេគេ រ៉ុនសៃនឹងរេស៊ីដង់ស្ទឹងត្រែង ។

ក្នុងឆ្នាំ ១៩២៣ លោកបានផ្លាស់មកធ្វើការនៅសាលាលុឃុន ភ្នំពេញ រួចទើបផ្លាស់ទៅសាលាក្រុមចោទទៀត ។ ក្នុងឆ្នាំ ១៩២៦ លោកបានប្រឡងជាប់ទីក្រមការ ។ ពេលនោះអ្នកស្រី ការប៉ឺឡែស ឃើញលោកចេះជ្រៅជ្រះខាងអក្សរសាស្ត្រ ក៏បានសុំឲ្យផ្លាស់ទៅធ្វើការ ក្រៅដំណែង ឯព្រះរាជបណ្ណាល័យ គឺក្រសួងពុទ្ធសាសនបណ្ឌិត្យ សព្វថ្ងៃនេះ ។ ធ្វើការនៅទីនេះបាន ៨ ឆ្នាំ ( ពី ១៩២៦ ដល់ ១៩៣៤) ។ បន្ទាប់ពីនេះតៗ មកលោកបានទៅធ្វើការក្នុងដំណែងផ្សេងៗ ដូចខាង ក្រោមនេះ :

– ចៅហ្វាយស្រុករលាប្អៀរ ខែត្រកំពង់ឆ្នាំង;
– ក្រុមជួយសម្ដេចចៅហ្វាវាំងជួន នៅព្រះបរមរាជវាំងក្នុងរាជ្យ ព្រះករុណា ខត្តិយកោដ្ឋ, ឋានន្តរជា ឧកញ៉ា ប្រសើរសូរ្យសក្ដិ ;

- ចៅហ្វាយស្រុកបាកាន ខែត្រពោធិ៍សាត់;
- ចៅហ្វាយស្រុកស្វាយទាប ខែត្រស្វាយរៀង ។

លោក ជុំ-មៅ មានគ្រឿងឥស្សរិយយស មេដាយ កុម្ម៉ង់ទ័រទឹន មេដាយផ្សេង ៗ ទៀតមានមណីសារាភរណ៍ជាដើម ។

ក្រោយបំផុត, លោកបានឡើងថ្នាក់ជាអនុមន្ត្រីលេខ ៣ ត្រូវផ្លាស់ពីស្រុកស្វាយទាបមកធ្វើការនៅទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចក្នុងឆ្នាំ ១៩៤៤ ។ វេលានោះ លោកកើតរោគបុកទងធ្លាក់ឈាមកាន់តែធ្ងន់ឡើងៗ ដរាបដល់ទទួលអនិច្ចកម្មទៅ ក្នុងកំណត់អាយុ ៤៤ ឆ្នាំ នៅថ្ងៃអាទិត្យ ២០ ខែសីហា ១៩៤៤ ក្នុងមន្ទីរពេទ្យព្រះកេតុមាលា ។

ចំពោះអក្សរសាស្ត្រ, ទោះបីលោកបានប្រឡងជាប់តែត្រឹមបដិ-ញ្ញាណបឋមសិក្សាបារាំង–ខ្មែរក៏ពិតមែន, តែជំនិះវិជ្ជារបស់លោកអ្នកផងទាំងពួង តែងសរសើរប្រៀបផ្ទឹមនឹងអ្នកមានសញ្ញាបត្រជាន់ខ្ពស់បាន ដូចជាអក្សរភាសាខ្មែរ, បារាំង, លាវនឹងសៀម លោកចេះប្រើការបានយ៉ាងស្ទាត់ម៉ត់ចត់ ដោយលោកធ្វៀតយកចិត្តទុកដាក់ណាស់ក្នុងការសិក្សា ។ អាស្រ័យហេតុនេះ, ទើបរាជការបានតាំងលោកកាលនៅធ្វើក្នុងក្រសួងពុទ្ធសាសនបណ្ឌិត្យនៅឡើយឲ្យធ្វើជាសមាជិក ១ រូប ក្នុងក្រុមជំនុំវចនានុក្រមខ្មែរ ដែលធ្លាក់មកលើភារៈសម្ដេចព្រះមហាសុមេធា-ធិបតី ជួន-ណាត ធ្វើបន្ទើយគ្រាតែចប់ស្រេច, ហើយពុទ្ធសាសនបណ្ឌិត្យ

បានបោះពុម្ពផ្សាយសព្វថ្ងៃនេះ ។ ម្យ៉ាងទៀតការរៀបចំបោះពុម្ពព្រះត្រៃបិដកជាដំបូង ក៏លោកបានជួយខ្នះខ្នែងយ៉ាងពេញកំឡាំង ដោយទទួលភារៈជាលេខានុការនៃក្រុមជំនុំចាត់ការបោះពុម្ពនោះ ។ ស្នាដៃដែលលោកបានប្រែពីភាសាបារាំងមកជាភាសាខ្មែរគឺ អំពីព្រះពុទ្ធសាសនា; រាជប្រវត្តិព្រះបាទជ័យវរ្ម័នទី ៧; ពុទ្ធោវាទានុសាសនី; មួយពាន់មួយយប់ (ប្រែបានពីវគ្គ ១ ដល់វគ្គ ៩ ហើយអាក់ខានប្រែតទៅទៀត ដោយហេតុត្រូវផ្លាស់ទៅធ្វើចៅហ្វាយស្រុករលាប្អៀរទៅ) ។ សៀវភៅទាំងអស់នេះ ពុទ្ធសាសនបណ្ឌិត្យបានបោះពុម្ពផ្សាយរួចហើយ ។ ក្រៅអំពីស្នាដៃខាងលើនេះ លោកជុំ-មៅ បានកាន់កាប់ការខាងទស្សនាវដ្ដីកម្ពុជសុរិយា ។ លោកបានតែងនិងប្រែរឿងរ៉ាវផ្សេងៗ ចុះផ្សាយក្នុងទស្សនាវដ្ដីនោះជាច្រើន ។ លោកជាអ្នកមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបកប្រែពីភាសាបារាំងមកជាខ្មែរ, ពីខ្មែរទៅជាបារាំងព្រមទាំងការសរសេរតែងឬស្សុត្រសុន្ទរកថានិងបាឋកថាជាដើម សឹងមានកល្យាណកិត្តិស័ព្ទ តាំងពីកាលជំនាន់នោះដរាបមកដល់សព្វថ្ងៃនេះ ។

ជុំ - មួង

# កត្រិចតុម្មុខ

ទិនករគេចរចុះទន់ទាប ទៅតាមសភាពលោកធម្មតា
បន្ទឹមលាក់ខ្លួនពួនអាត្មា នាទិសបច្ចិមាចោលរស្មី ៗ
ក្រហមព្រឿងៗលឿងចម្រុះ ចែងចាំងផ្លាស់ផ្ទុះលើផែនដី
ក្រាលពាសធម្មជាតិស្រទន់ខ្ចី ពណ៌ឆ្នូតពីសីកាត់ជើងមេឃ ៗ
លាលិបលិចចុះសន្សឹមទៅ មនុស្សសត្វដែលនៅពេញគម្រែក
ស្រងូតស្រងាត់ស្ងប់ស្ងាត់ពេក រវើកតឹងតុះស្អុះស្អាប់ប្រាណ ៗ
វិកាលដាលខ្មៅងងឹតឈប់ បិទបាំងពិភពគ្រប់ដែនដាន
ដល់វេនត្រើដណ្ដើមហាន តាមដោយលំអានជាលំដាប់ ៗ
ព្រះពាយផាយផាត់កាត់ទៅមក បុករុញពពកពពួនអំពួ
ខ្មៅកកងងឹតជិតខានខាប់ ប្រានចេញប្រញាប់ឲ្យឃ្លាតឆ្ងាយ ៗ
អាកាសស្រឡះស្អាតសំខាន់ ព្រះច័ន្ទរះភ្លេតភ្លឺត្រឆាយ
រស្មីស្រអែតចាំងសព្វសាយ ឯផ្កាយក៏រះបន្តគ្នា ៗ
ចោមជាបរិវារការពារពិត ខ្លះនៅនៃបទិសជិតប្រន្ទា
ខ្លះនៅឃ្លាតឆ្ងាយផ្សាយអាកា ព្រោងព្រាយលាយគ្នាចម្រុះញឹក ៗ
អ្នកដែលស្លូតស្ងប់ចប់ធុញណាយ បែរបានសប្បាយយ៉ាងពន្លឹក
ដោយសារពន្លឺភ្លឺអធិក ផ្តួចទឹកចេញចរកែកំសាន្ត ៗ
គន់ផ្លូវទន្លេចតុម្មុខ ទឹកពេញបន្ទុកពន់ប្រមាណ

លិចអស់កោះត្រើយគគសល់វាន ហូរច្រានក្អួចច្រាល់គាល់មាត់ច្រាំង ៗ
ត្រូវខ្យល់ដំនោរផោរបក់មក កើតជារលករំជួយខ្លាំង
ទូកតូចផ្សងផ្សាងអុំប្រឆាំង តតាំងកាត់ទឹកនឹកភ័យក្រៃល ៗ
ផ្អែកផ្អួតរលកដូចព័ណ៌ប្រាក់ ផ្អែក ៗ ឥតអាក់ហាក់ផលផែល
ដោយប៉ះពន្លឺព្រះច័ន្ទដែល ចែងចាំងភ្លាត់ភ្លែលស្រស់ស្រទន់ ៗ
ខាងឯអរីយ៍ក្សត្រទិសបូព៌ា ប្រទីបផ្កាលាលឡោបលន់
ហែតាមមាត់ច្រាំងច្រើនពេកពន់ គយគន់គឺពួកនេសាទត្រី ៗ
ងាកទៅខាងត្រើយជ្រោយចង្វា . ព្រោងព្រាតភ្លឺថ្លាដោយរស្មី
ចង្កៀងវៀងភាយតាមវិថី ប្រុសស្រីដើរលេងលំហែកាយ ៗ
នៅខាងមាត់ច្រាំងដំណាក់ផែ ទំនែកហូរហែលក់ចែកចាយ
ស្រីយួនខ្លួនស្អាតឲ្យកនាយអាយ ប្រុស ៗ សប្បាយទិញស៊ីលាន់ ៗ
យូរ ៗ ឮស្គូរមាត់ខ្វង់ស្រាក ស្រែកយំខ្លាក ៗ គួរភ័យភ័ន្ត
គេនាំគ្នាជេរប្រទេចផ្តាន់ ស្រែកទន់ជាមួយសម្រែកព ៗ
"មេចោរហ៊ានហោចខ្ទោចចម្រុះ អន្ទរធានចុះកុំយូរយារ
កុំហើរស្រែកយំទំរោក ឲ្យហង់វេទនាស្លាប់ក្សិណក្ស័យ ’ ៗ
តាមចាស់បុរាណបានផ្ញើមក សត្វនេះមិនរកស៊ីពេលថ្ងៃ
រកស៊ីតែយប់គាចព្រៃ កែខៃបំផ្លិចបំផ្លាញគេ ៗ
ថាក់ជាពលនៃស្តេចខ្មោច ចង្រៃអសោចិ៍ពីបុព្វ

ស្តេចខ្មោចតែងប្រើហើររិះរ យកព្រលឹងគេសត្វក្ខូមិហារ ៗ
ខ្វែងអើយខ្វែងស្រោកលំបាកម្ល៉េះ រកស៊ីសោះអេះហើរហាត់ប្រាណ
ត្រូវមាត់គេជេរតតសល់ខាន កម្មអ្វីទៅបានជាយ៉ាងហ្នឹង ៗ
កត្រើយបយន់បន្តិចទៅ សែងចន្ទួសន្ទោចប្លាស់តែរឹង
ក្តីសាយផាសពាសពេញទំហឹង រ៉ាយោបក់រឹងត្រផាក់កាយ ៗ
លើចុងអំពិលខាងមុខរាំង អស់ទាំងសត្វក្អែកបែកខ្ចាត់ខ្ចាយ
ខ្វះហើរបៀសចេញទៅទីឆ្ងាយ ខ្វែកខ្វកប្រញាយចឹកឈ្លោះគ្នា ៗ
ដើមចមដម្លោះទំនងដាក់ មួយដេកមួយភ្ញាក់នាំពាធា
រង្គើមែកអញ្ចក្នាញ៉មហិមា ពះរាំមិនដឹងគេដេកពួន ៗ
នៅលើដើងម៉ាស៊ុម៉ងវែង ប្រុសស្រីផ្អែកជ្រែងសំងិលខ្លួន
ខ្វះប៉ះសង្ក្រាទើបប្ដូបប្ដួន កេះកៀវប្រដួនសប្បាយក្រៃ ៗ
អ្នកខ្វះតតបានដើងម៉ាទេ ពឹងមាត់ទន្ទេគ្រាន់អាស្រ័យ
អង្គុយសណ្ដូកទប់ជ្រែងដៃ មៀងមើលផលស័យកំសាន្តចិត្ត ៗ
ខ្វះខ្វាបក្រែងស្រើងោះគេចកៃ ខំកួតស្បថស្បែយកសុចរិត
ថាបើវៀចវេរក្បត់ផិត ហើយមិនអាណិតដល់ចរណៃ ៗ
នោះសូមព្រះអង្គដងកើអើយ កាប់កបង្ហើយឲ្យហិនហៃ
កុំឲ្យខ្ញុំឃើញពន្លឺថ្ងៃ ក្បីណក្បីយជាជាងរស់ក្បត់ស្រី ៗ
ខ្វះកៀកដៃគ្នាឆ្ងាយពីគេ មិនដឹងរិះរេពីរឿងអ្វី
តែស្មានមិនខុសប្រុសនឹងស្រី គ្មានអ្វីក្រៅផ្សេងពីការទុង ៗ

ខ្វះទៀតធ្មៀតក្រោមដើមអំពិល ងងឹតព្រិល ៗ ឃើញខ្មៅស្ងុង
ប្រឡែងប្រឡូសអូសព្រយុង ពីព្រោះរឿងទុងដែរមើលទៅ ៗ
អ្នកមានសង្សារសែនសប្បាយ កៀកកេះភ្អាកភ្អាយទាល់យប់ជ្រៅ
ឯងអត់ក្រៀមផ្អេះកេះតែភ្លៅ អ៊ូស៊ូនៅលេបទឹកមាត់ ៗ

មើលគេត្រឹះ ៗ ទន្ទឹះចិត្ត ព្រោះផ្សិតមានដៃវែតប្រាសព្រាត់
ទុកម្អីហ្នឹមកខាំងឃាត់ បំភ្លាត់ឲ្យឃ្លាងពីកល្យាណ ៗ
ទឹកសព្វ ៗ ទៅកាន់តែព្រួយ ស្ទើរប្រែរលួយក្នុងសន្ដាន
ដល់ណាស់ផាណាស់ទ្រាំមិនបាន ស្រែកប្រៀងកំសាន្តថាហាហៃ=

តាំងពីចិត្ត គិតពីបង បងស្នេហា
លើជីវ៉ា ថាជីវិត វរមិត្រថ្លៃ
នៅមិនស្ងៀម រៀមមិនស្ងាត់ បាត់អាល័យ
ហាក់ស្រវៃ ដៃស្រមោល ពោលជិតប្រាណ ៗ
ពេលបងគេង លេងបងគង រងលើខ្នើយ
ធ្លាប់បានកើយ ហើយបានកិត ជិតកុំឆាន
ធ្លាប់ប្រឡែង តែងប្រឡូក លូកស្មោះស្មាន
តែកំសាន្ត ហានកំសត់ កត់កាលណោះ ៗ
ឥឡូវប្រែ តែមិនប្រប គប់ដូចចិត្ត
ខកខានស្និទ្ធ ខិតខានស្នេហ៍ បែរបែកស្មោះ

| | | |
|---|---|---|
| ឥតនឹកនា | គ្នានឹកទិត្យ | គិតស្រណោះ |
| ពុំគួរសោះ | ដោះដៃសូន្យ | ណាអូនទៅ ។ |
| ប្រសិនប្រាណ | បានមកប្រប | កបវិញអេះ |
| រួមសំណេះ | គេះសំណាល | កាលហួសទៅ |
| បងបីដោម | ដោមដុង្គធើត | ទើតលើត្បៅ |
| នាយប់ជ្រៅ | នៅយប់ជ្រុល | ពុលតណ្ហា ។ |
| សែនតម្រេក | ត្រេកតម្រង | អង្គឥតអាក់ |
| ពេញចិត្តស្ម័គ្រ | ប្តាក់ចិត្តស្មោះ | អស់ក្រឡា |
| កែក្រខ្យែ | ដៃក្រខ្យិប | បិចក្ព្រា |
| នៃកល្យាណ៍ | ថ្វាកល្យាណ | ឲ្យបានស្កប់ ។ |
| ចាប់ក្រសារ | ការក្រសោប | ឱបមាសង្អិន |
| កៀកសង្កិន | សិទសង្កត់ | បត់ត្រឡប់ |
| ស្ទាបបបោស | កោសបបែល | អង្អែលសព្វ |
| រួបបញ្ចប់ | គប់បញ្ចើច | សើចក្អាកក្អាយ ។ |
| ឧបណ្ដូល | មូលបណ្ដាច់ | សាច់ទ្រលន់ |
| កង់ល្វតល្វន់ | ទន់ល្វតល្វាស | ទិកសធ្វាយ |
| បើជាពៅ | នៅជាពិត | ផិតវៀនអាយ |
| វៀមស៊ូចាយ | កាយស៊ូចេញ | ដេញតាមស្ងួន ។ |

តែនេះផុត សុខនេះផុង ប្រឹងមិនកើត
ព្រោះឆោមឆើត ស្ងើតឆោមឆាយ ផាយបាត់ខ្លួន
គ្មានដំណឹង ដឹងដំណាល កាលនឹមនួន
នៅស្រុកយួន ពួនស្រុកយ័ក្ស ស្នាក់ត្រង់ណា ៗ
នេះស្រឡាញ់ បាញ់ស្រឡះ ប៉ះលើក្តៅ
សឹងសោកសៅ ម៉ៅសោកសាំ រកាំផ្សា
នាំធុរឆាប ឆាបធុរឆេះ ប្រេះខុក
បង់អាសា ណាអសោច៍ ខ្លោចផ្សិតស្រី ៗ
ហេតុផុះប្ទះ អេះផ្ទុះបឹង គួរប្រឹងខាត់
លះវិបត្តិ កាត់វិបាក ចាកលោកិយ
រៀនធម៌អាថិ សារធម៌អាថ៌ បាបបាលី
សាងចិត្តថ្មី បីដូចថ្ម គេទៅអើយ ! ៗ

ញុង - សៀង

ឃ្លាន អស់កំឡាំងហេវល្វើយល្វើង
ឆ្ងាញ់ ណាស់ពេលហ្នឹងឥតឧបមា
ស្រឡាញ់ ពេញចិត្តសុខស្នេហា
ល្អ ឥតនរណាមកផ្ទឹមបាន ៗ

ញ. ស.

# ភាសាបាលីក្នុងប្រទេសកម្ពុជា

ភាសាបាលីមានដើមកំណើតនៅប្រទេសឥណ្ឌា គេប្រើជាពាក្យសំរាប់ចងក្រងរៀបរៀងគម្ពីរដីកាឬរឿងព្រេងផ្សេងៗ កាលដើមពុំសូវជាមានរបៀបប៉ុន្មានឡើយ ចំណេរតមកអ្នកសិក្សាទាំងអ្នកនិពន្ធបានរៀបរៀងភាសានេះឲ្យមានរបៀបបែបផែនរឹងរិតតែចំណានឡើងៗ ដោយវេយ្យាករណ៍ទាំងវោហារប្រព្រឹត្តទៅតាមសម័យលោកនិយមៗ

ដំណាន់ពុទ្ធកាល ភាសានេះពុំសូវមានរបៀបវេយ្យាករណ៍ប៉ុន្មានឡើយ ទាំងពាក្យពេចន៍ក្នុងប្រយោគនីមួយៗ ក៏ពុំសូវស្រួលស្តាប់ ដូចពាក្យក្នុងព្រះត្រៃបិដកដែលព្រះថេរៈទាំងឡាយរៀបរៀងក្នុងកោះលង្កាយកតាមវោហារតាំងពីសង្គាយនាទី ១ មកនោះ ឃើញថាមានពាក្យស្រំដែលច្រើន មើលអស់ពេលច្រើនតែបានសេចក្តីតិច លុះប្រែមកជាភាសាខ្មែរក៏នៅតាមទំនងនោះដែរ បើអ្នកដែលស្ទាត់ជំនាញខាងអានអក្សរក្រឡេកភ្នែករហ័សទើបអាចអានសំដៅយកតែពាក្យចំឡែកៗ រំលងពាក្យស្រំដែលនោះបានៗ តាមទំនងនេះព្រះត្រៃបិដកដែលប្រែជាភាសាខ្មែរប្រសិនបើមានអ្នកដែលសំបូរណ៍ដោយធនធាន អាចបាត់បែងបោះពុម្ពមួយបែបផ្សេងទៀត កាត់យកតែពាក្យចំឡែកៗ កុំដាក់ពាក្យផ្ទួនៗ គ្នានោះនឹងបានជាព្រះត្រៃបិដក ១ ចប់យ៉ាងខ្លីដំឡែកតិច អ្នកអានក៏ឆាប់ចប់ឆាប់ចេះយ៉ាងងាយស្រួលបំផុតៗ

ចំនួនជា ១.០០០ ឆ្នាំតមកទៀត ភាសានេះចំរើនកើនឡើងមានរបៀបល្អប្លែកជាងពីដើមឆ្ងាយណាស់ ដូចយ៉ាងពាក្យក្នុងអដ្ឋកថាផ្សេងៗ សឹងមានរបៀបវេយ្យាករណ៍ទាំងវោហារដ៏ជ្រាលជ្រៅ សូម្បីតែភាសាខ្មែរក្នុងសម័យនេះ បើនឹងយករបៀបប្រយោគនឹងសំនួនយោងទៅប្រៀបផ្ទឹមស្មើរតែពុំស្មើនឹងបាឡីជាន់នោះឡើយ ។

ចាប់ពីត្រឹមជំនាន់អដ្ឋកថារៀងមក ភាសាបាឡីដូចជាគ្មានចំរើនប្លែកពីជាន់ដើមទេ ដរាបមកដល់សព្វថ្ងៃអ្នកសិក្សាក៏រៀនតែរបៀបបែបចាស់ដែលមានទុកមកស្រាប់ពុំមានអ្នកនិពន្ធរៀបរៀងវេយ្យាករណ៍ឲ្យប្លែកពីនោះទៀតឡើយ ។ ហេតុនេះហើយបានជាសម័យសព្វថ្ងៃពួកអ្នកបាឡីចេះតែមើលបាឡីគេស្រាប់ និយាយពុំបានសរសេរពុំបានព្រោះរបស់ក្នុងលោកចេះតែមានកើតឡើងចំឡែកៗ គ្មានដាច់ មានឈ្មោះផ្សេងៗសំរាប់ហៅ ឯភាសាបាឡីក៏ឈប់ស្ងៀមតាំងពីជាន់អដ្ឋកថាគ្មានឈានទៅមុខ ១ ជំហានសោះ ពាក្យសំរាប់ហៅរបស់ដែលកើតឡើងថ្មីក៏គ្មាន បើយ៉ាងហ្នឹងអ្នករៀនបច្ចុប្បន្នឲ្យនិយាយភាសាបាឡីឯណាបាន? ទឹកខ្មៅ ស្លាបប៉ាកកា ដងប៉ាកកា, ខ្មៅដៃ, សាប៊ូ, គុយទាវ ។ ល ។ ឲ្យហៅជាបាឡីថាដូចម្ដេច? ។

ការរៀនបាឡីក្នុងប្រទេសខ្មែរ= ខេមរៈកុលបុត្រនាំគ្នាសិក្សាភាសាបាឡី តាំងពីយូរយារណាស់មកហើយ ដោយភាសានេះផ្ទុកពេញទៅ

ដោយព្រះពុទ្ធវចនៈដែលជាសាសនាសម្រាប់ប្រទេស ហើយជាភាសា មានលំនាំស្រដៀង ៗ គ្នានឹងសំស្ក្រឹត ។ បាឡីនឹងសំស្ក្រឹតនេះ ខ្មែរយកមកប្រើជាភាសារបស់ខ្លួនស្ទើរតែពាក់កណ្ដាល តាំងពីសម័យព្រេងនាយរហូតមកដល់បច្ចុប្បន្ន ។ ភាសាបាឡីនេះ ចំរើនយ៉ាងឆាប់រហ័សក្រៃលែង ព្រោះចំនួនអ្នករៀនកាន់តែច្រើនឡើង ៗ គ្មានថយ, តែឯរបៀបសិក្សាវិញ ដូចជាពុំទាន់ផ្លាស់ប្រែប៉ុន្មានឡើយ ។ ដូច្នេះ, គួរណាស់តែផ្លាស់របៀបរៀនឲ្យបានស្រួលឆាយជាងមុន ឲ្យសមតាមឋានៈរបស់ប្រទេសដែលមានអ្នកចេះភាសាបាឡីច្រើន, សូមទាញឧទាហរណ៍ពីការរៀនអក្សរខ្មែរជាបែបធៀប ។

ខ្មែរពីដើមពុំសូវមានចេះអក្សរដូចសព្វថ្ងៃនេះទេ, តាមស្នាមមើលទៅប្រហែលជាមកពីលំបាករៀន ដោយគ្មានរបៀបស្រួលបួល ។ ក្មេងរៀននៅវត្តដំបូង រៀនសរសេរដោយដីសរនឹងក្ដារឈ្នួន ។ កង់ដំនាន់ទី ១ រៀនសរសេរឲ្យចាំគ្រប់តួអក្សរ ។ ទី ២ រៀនមើលពាក្យកាព្យឃ្លោង ។ ទី ៣ រៀនមើលពាក្យរាយដែលហៅថាសាស្ត្រទេសន៍មានលាយពាក្យបាឡីផង ។

កង់ដំនាន់ទី ១ រៀនតែសរសេរសុទ្ធគ្មានណែនាំឲ្យប្រកបផង ហើយតួអក្សរនោះបំបែកទៅច្រើនពេក រៀនទៅមុខភ្លេចឯក្រោយ ពុំសូវមានពាក្យពន្យល់ឲ្យបែកគំនិតទេ, ជួនកាលក្មេងធុញទ្រាន់ក៏រត់ចោលការសិក្សាទៅ ។

ក្នុងជំនាន់ទី ២ រៀនមើល – ក្មេងនៅខ្ចីសេចក្ដីពេក ពុំដែលបានប្រកបអក្សរមួយតួសោះ ស្រាប់តែយកពាក្យកាព្យឃ្លោងដែលជាស្នាដៃកវីនិពន្ធយ៉ាងជ្រាលជ្រៅទៅឲ្យរៀនមើល ពុំស្រូវពន្យល់ពីរបៀបប្រកបផ្សំតួអក្សរផង , មើលទន្ទេញចាំមាត់ស្ទើរតែពុំយល់របៀបប្រកបសោះ តែដោយអំណាចថាដដែល ៗ យូរពេកពីរ · បីឆ្នាំខ្លះទ្រាំមិនបានក៏រត់ចោលការសិក្សាទៅ , បើទ្រាំបានក៏បានចេះតែត្រឹមមើលដាច់ប៉ុណ្ណោះ តែស្ដាប់សេចក្ដីក្នុងប្រយោគដែលខ្លួនរៀនអាននោះពុំបានទេ ដូចគ្នានឹងអ្នកដែលចេះសូត្រធម៌ជាភាសាបាលី ឬអ្នកដែលចេះអានអក្សរបារាំងតែស្ដាប់សេចក្ដីមិនបានដូច្នោះដែរ; ចំណែកការសរសេរលើក្រដាសឬចារលើស្លឹករឹតតែក៏ពុំទាន់ចេះនៅឡើយ ។

ក្នុងជំនាន់ទី ៣ រៀនទេសន៍តាមអក្សរ ក៏រឹងរឹតតែលំបាកណាស់ទៅទៀត ចួនណាអានទៅត្រូវតាមអក្សរ តែគ្មានស្ដាប់បានសោះព្រោះចំណេះខ្សោយតាំងពីជំនាន់ទី ២ ឯណោះទៅហើយ ។

តែក្រសួងសិក្សាអក្សរខ្មែរមិនព្រមបណ្ដោយទុកឲ្យមានការលំបាកតទៅទៀត ខំឆ្លៀតយកតាមបែបផែនប្រទេសដទៃខ្លះ តាមគំនិតរបស់ខ្លួនខ្លះកែប្រែរបៀបរៀនជាក្បួនរៀនអក្សរបានច្រើនបែបហើយបង្រៀនទៅឃើញចាប់ចេះដូចប្រាថ្នាមែន មកពីលលករកចំណេះជាន់ចាប់មកបង្រៀនដោដំបូងដំរូវដល់ក្មេងមិនធ្លាប់កប់ប្រសប់នឹងការសិក្សាដល់ជួបប្រទះកាលណា

ក៏មិនជាធុញទ្រាន់ប៉ុន្មាន រួចហើយទើបបង្រៀនអានពាក្យពិបាកឡើងបន្តិចម្តងៗ ដូចគេដឹកដៃមនុស្សឡើងច្រាំងដែលទេរទាបស្រួលល្មមកំឡាំងឡើងទៅរួចបាន ។ ដល់ពេលចេះអានក៏ចេះតាំងសរសេរចេះតាំងស្តាប់សេចក្តីនឹងតែងពាក្យពេចន៍កើតដោយខ្លួនឯងទៀត ។

ឯការសិក្សាភាសាបារាំងសព្វថ្ងៃហាក់ដូចជាពុំទាន់ជឿនលឿននៅឡើយ ព្រោះនៅក្នុងការពិបាករៀនបន្តិចដូចគេដឹកដៃមនុស្សឡើងច្រាំងចោត ប្រសិនបើបង្កើតរបៀបរៀនឲ្យងាយជាងនេះទៅទៀតប្រហែលជាស្រួលដល់ការសិក្សា គឺរៀនវេយ្យាករណ៍ រៀនប្រែបារាំងងាយៗជាមុនជាបារាំងតែងឡើងចំបុកបារាំងក្នុងគម្ពីរតែដកយកត្រង់កន្លែងពាក្យរាក់ៗ រៀនឲ្យស្តាប់ពាក្យបារាំងបាន គឺប្រែបានប៉ុន្មានត្រូវយល់សេចក្តីប៉ុណ្ណោះហើយចេះសរសេរតែងជាភាសាបារាំងផង ទើបរៀនដេញទៅជ្រៅបន្តិចម្តងៗតាមរបៀបដែលបណ្តុះផ្សាំប្រាជ្ញាទៅខួរ ឲ្យចាស់ក្លាឡើងទៅតាមលំដាប់ដូចអ្នកឡើងជណ្តើរមិនឈានរំលងកាំខាងក្រោម ។ ការសិក្សាសព្វថ្ងៃឃើញប្រើជំហានវែងបន្តិច កុលបុត្រដែលរៀនវេយ្យាករណ៍រួចហើយត្រូវស្រូតទៅប្រែគម្ពីរអដ្ឋកថាធម្មបទ ចាប់តាំងពីពាក្យនមស្សការរៀងទៅ; ក៏ពាក្យនមស្សការនោះជាពាក្យរបស់អ្នកប្រាជ្ញ ដែលមានគំនិតដ៏ជ្រាលជ្រៅលេងសំនួនឃោងរេហារមុតប្រាយយ៉ាងអស្ចារ្យ ជាពាក្យសំកប់អ្នកប្រាជ្ញផងគ្នាមើលហើយកោតថ្វីដៃអ្នកនិពន្ធ, លុះដាក់ពាក្យនេះមកឲ្យអ្នក

រៀនចុះមើលស្ដាប់វិញ ដូចជាហឹងត្រចៀកគ្មានយល់អ្វីសោះ ព្រោះហួសវិស័យបញ្ញាឆ្ងាយពេក ៗ ផុតពីពាក្យនមស្ការទៅដល់រឿងចក្ខុបាលត្ថេរ មានអត្ថរបស់គាថាជាពាក្យបរមត្ថទាំងស្រុង ឮតែពោលពីចិត្ត, ចេតសិក ខន្ធ, ធាតុ, អាយតនៈ, និស្សត្តនិជ្ជីវធម៌ ក៏រឹងរឹតតែធ្ងន់ដល់ប្រាជ្ញាដែលទើបនឹងបណ្ដុះចំណាស់ទៅទៀត ដូចគ្នានឹងក្មេងជាតិខ្មែរដែលទើបនឹងសរសេរអក្សរចាំដៃក៏ឲ្យមើលសាស្ត្រច្បាប់ក្រម មានអត្ថដ៏ជ្រាលជ្រៅមានពាក្យថា: "អាចមកបំបួស ហេតុចង់សម្ភារ ប្រើចង់អនុពាល រៀនដោយក្រមច្បាប់" ដូច្នេះជាដើម ៗ រសជាតិសំដីនេះគ្មានជ្រួតជ្រាបចូលទៅក្នុងហឫទយរបស់ក្មេងនោះឡើយ ៗ

ម្យ៉ាងទៀត, ការបង្រៀនបាឡីក្នុងវិជ្ជាសង្ខ្យា គ្មានឃើញបង្រៀនពីលេខសង, បូក, គុណ, ចែកផងឡើយ លុះដល់រៀនជ្រៅទៅៗ ក៏ស្រាប់តែប្រទះឃើញពាក្យក្នុងព្រះពុទ្ធសាសនា មានប្រើលេខចែកគុណជាច្រើន ដូចពាក្យថាតណ្ហាខាងក្នុង ៦ ខាងក្រៅ ៦ បូកបូលគ្នាជា ១២ តណ្ហាទាំង ១២ គុណនឹងកាលទាំង ៣ ជា ៣៦ ដូច្នេះជាដើម ៗ បើក្នុងព្រះអភិធម្ម ក៏រឹងរឹតតែប្រើលេខណាស់ទៅទៀត ដូចគិតពីអាយុទេវតាព្រហ្មជាដើម ៗ

អ្នករៀនភាសាបាឡីសព្វថ្ងៃមានចំនួនច្រើនរាប់រយរាប់ពាន់នាក់ទៅហើយ; អ្នកទាំងនោះនឹងធ្វើសមណធម៌ឲ្យបានសម្រេចគុណវិសេសក្នុង

ជាតិនេះទាំងអស់គ្នាឃើញថាពុំកើតទេ, មុខជាបែរមកប្រកបការចិញ្ចឹមជីវិតវិញពុំខាន, ហេតុនេះការសិក្សាភាសាបាលី ដើរផ្លូវឃ្លាងពីវិជ្ជាផ្លូវលោកពេកពុំបានឡើយ ។ អ្នករៀនបាលីច្រើនខ្វះបំណោះនពន្ធ, ភូមិសាស្ត្រ, ពង្សាវតារ ម្ល៉ោះហើយបើបែរមកខាងផ្លូវលោកវិញ មានវិជ្ជាតិចមុខនៅក្នុងខ្លួន គឺសរសេរបំឡេងនឹងតែងសេចក្តីខ្លះៗ ហើយសេចក្តីនោះប្អូនគាល់ច្រើនតែជាពាក្យដែលគេនិយាយក្នុងផ្លូវសាសនាផង, គួរឲ្យអាសូរពេក ។

រៀបរាប់មកប៉ុណ្ណោះ គ្រាន់តែជាសេចក្តីអធិប្បាយតាមយោបល់របស់ខ្ញុំម្នាក់ឯង ហើយសរសេរបង្ហាញដល់លោកអ្នកប្រាជ្ញខាងភាសាបាលីដោយចង់ដឹងថាការយល់ឃើញបែបនេះស្របឬផ្ទុយច្រើនជាង ។

ទីបំផុត, ខ្ញុំសូមគោរពចំពោះបណ្ឌិតទាំងឡាយ ទោះបីសេចក្តីអធិប្បាយនេះខុសត្រូវយ៉ាងណា សូមមេត្តាកែតំរង់ឲ្យទាន ដើម្បីជាការជួយយោងមុខការសិក្សាឲ្យបានចំរើន ។

មៀវ - នន្ទ

សៀនសាលាស្រុករលាប្អៀរ

កំពង់ឆ្នាំង

បបកទមនកៈជំរាបថា  សូមលោកម្ចាស់ជ្រាបដូចសេចក្តីតទៅនេះ:

៩៨ – កិច្ចការបន្តិចបន្តួចនៃម្ចាស់ផែនដី  បុគ្គលមិនគប្បីនិយាយឲ្យពួកជនកណ្តាលទីប្រជុំឡើយ  នេះជាពាក្យបណ្តាំព្រះព្រហស្បត៌ ។

សូមលោកជាស្តេចចតុប្បាទជ្រាបតាមសេចក្តីដែលខ្ញុំបានជំរាបនេះ ព្រោះថា:

៩៩ – មន្ត្រីការសំងាត់ឲ្យដឹងដល់ត្រចៀក ៦ ហើយ តែងបែកធ្លាយ,  បើត្រឹមតែត្រចៀក ៤ មិនបែកធ្លាយទេ  ព្រោះហេតុនោះ អ្នកប្រាជ្ញគប្បីវៀរត្រចៀក ៦ ដោយប្រយ័ត្នប្រយែងគ្រប់កាលទាំងពួង ។

លំដាប់នោះ សត្វទាំងឡាយគឺខ្លា  ខ្លារខិន នឹងបបកដែលបិតនៅចំពោះមុខទាំងអស់  លុះបានឮពាក្យនោះក្នុងទីប្រជុំយល់បំណងបិង្គលកៈហើយ  ក៏បបួលគ្នាថយទៅឆ្ងាយក្នុងមួយរំពេចនោះ ។  ក្នុងពេលនោះ បបកទមនកៈនិយាយសួរសីហៈថា “បពិត្រលោកជាស្តេចសត្វចតុប្បាទ! លោកចេញទៅដើម្បីផឹកទឹក  ហេតុអ្វីក៏ស្រាប់តែថយក្រោយហើយមកនៅក្នុងទីនេះវិញ? ។  បិង្គលកៈញញឹមក្រៀមដោយអៀនខ្មាសឆ្លើយប្រាប់ថា “មិនមានការអ្វីទេ” ។ បបកទមនកៈនិយាយទៀតថា “ថា បើការនេះ មិនជាអ្វីទេ លើកទុកមួយអន្លើទៅសិនចុះ ព្រោះថា :

១០០ – បុគ្គលគប្បីលាក់កិច្ចការខ្វះដែលត្រូវលាក់ មិនឲ្យប្រពន្ធ បរិវារ មិត្រសំឡាញ់ ឬកូនចៅដឹងឮឡើយ, អ្នកប្រាជ្ញ ពិចារណានូវ កិច្ចការនោះៗ ទោះគួរក្តី ពុំគួរក្តី រួចស្រេចហើយទើបពោលដោយការ ខានមិនបានដាច់ខាតផង" ។

លុះបិង្គលកៈបានស្តាប់ចបកទមកៈហើយគិតថា "កាលនេះឃើញ ដល់កាលគួរហើយ បើដូច្នោះអាត្មាអញនឹងប្រាប់បំណងអាត្មាអញឲ្យវាដឹង មុនគេ, ព្រោះថា :

១០១ – បុគ្គលណាប្រាប់សេចក្តីទុក្ខ ដល់ម្ចាស់ដែលជាអ្នកស្គាល់ គុណសម្បត្តិផ្សេងៗ ដល់អ្នកបំរើដែលមានគុណសម្បត្តិ ដល់ប្រពន្ធ ដែលប្រព្រឹត្តតាមដំបូន្មាន ដល់មិត្រដែលមានចិត្តមិនទៀងចាង បុគ្គល នោះនឹងបានសេចក្តីសុខ" ។

បិង្គលកៈប្រាប់ថា "នែទមនកៈ ឯងមិនឮសំឡេងអ្វីលាន់គងរំពង ព្រៃខាំងនៅឆ្ងាយនោះទេឬអ្វី?" ។ ចបកទមនកៈឆ្លើយឡើងថា "ព្រះ បពិត្រ! ខ្ញុំបាទឮដែរ ចុះសំឡេងអ្វីនោះ?" ។ បិង្គលកៈឆ្លើយប្រាប់ ថា "នែសំឡាញ់អើយ! យើងមិនដឹងដែរ បានជាយើងចង់រត់ចេញ ពីព្រៃនេះ" ។ ចបកទមនកៈសួរថា "ចុះហេតុអ្វី បានជាលោកចង់ ចេញពីព្រៃនេះ?" ។ បិង្គលកៈប្រាប់ថា "សំឡាញ់! ថ្ងៃនេះមាន សត្វអ្វីមួយប្លែកបូលមកនៅក្នុងព្រៃយើង ស្រែកសំរែកលាន់ឮគឹកកងរំពង

ព្រៃ បើសំឡេងវាធំដល់ម្ល៉ោះ គង់រូបរាងវាក៏ធំសម្បើមសំនឹងសំឡេងវានោះដែរ ។ ចចកទមទក:ឆ្លើយឡើងថា “ព្រះបពិត្រ ! លោកម្ចាស់សព្វបើគ្រាន់តែឮសំឡេងវាប៉ុណ្ណោះ ក៏កើតភ័យតក់ស្លុតរន្ធត់ព្រះទ័យដែរ ? ធ្វើដូច្នេះមិនសំដល់បុទ្ធិតេជៈលោកម្ចាស់ទេ, ព្រោះថា ៖

១០២ – ទឹកទំលាយទំនប់បាន មន្ត្រីដែលគេមិនតមតាមត្រណាមបំផ្លាញអ្នកកាន់បាន, ពាក្យញុះញង់បំផ្លាញមិត្រភាពបាន ឯសំឡេងបំភ័យមនុស្សកំឡាចបាន” ។

ដូច្នេះ លោកម្ចាស់មិនគួរគប្បីលះបង់ចោលព្រៃ ជាកេរ្តិ៍ដែលបុព្វបុរសលោកម្ចាស់បានរក្សាមកហើយនោះទេ បើទុកជាមានសំឡេងគឹកកង់រំពង់ព្រៃផ្សេងៗ មានសំឡេងគោរ ខ្លុយ ពិណ សំភោរ ជួង ស័ង្ខ ស្គរធំ ជាដើម ក៏លោកម្ចាស់មិនគួរនឹងភ័យខ្លាចសព្វបើគ្រាន់តែឮសំឡេងគឹកកង់នោះឡើយ ព្រោះថា ៖

១០៣ – នរជនណាមិនបាត់សេចក្តីអង់អាចក្លាហានតស៊ូសត្រូវសូម្បីស្តេចមហាអំណាចមានបុទ្ធិគួរសប់សែង នរជននោះមិនចាលចាញ់ទេ ។

១០៤ – ព្រះធាត្រី(១) ក៏សំដែងក្តីភ័យខ្លាចឲ្យគេឃើញច្បាស់ តែ

---

១ ព្រះព្រហ្ម ។

សេចក្ដីអង់អាចក្លាហាននៃលោកជាវីរបុរសមិនបាត់បង់ទេ,ក្នុងនិទាឃកាល ទឹកបឹងបួររីងរំហួតអស់ តែមហាសមុទ្រនៅតែពេញព្រៀបដដែល ។

១០៥ – ជនណាមិនព្រួយបារម្ភក្នុងកាលវិបត្តិ មិនរីករាយហួសហេតុក្នុងកាលសម្ប័ទ គឺក្នុងកាលរុងរឿង មិនតក់ស្លុតរន្ធត់ក្នុងកាលសង្គ្រាម មាតាដែលបង្កើតកូនបែបនោះប្រកបដោយលិលក:[១] ជាកំពូលត្រ័យកពយ៉ាងនេះក្រមានណាស់ ។

១០៦ – ជនណាតែងទោរទន់ទៅតាមវិកលយសស័ក្តិ មានចិត្តស្រាល ព្រោះចិត្តឥតខ្លឹមសារឥតមានៈ កំណើតនៃជននោះមានគតិស្មើគ្មានទីងដើមស្មៅ ។

១០៧ – នរជនណា ជួបប្រទះអំណាចជនដទៃ ហើយត្រឡប់ទៅជាទន់ខ្សោយខ្លាចគេ មិនតាំងនៅក្នុងការម៉ឺងម៉ាត់ នរជននោះ មានប្រយោជន៍អ្វី គ្រាន់តែមានរូបដូចគ្រឿងអលង្ការធ្វើពីជ័រ ។

បើលោកម្ចាស់ បានជ្រាបសេចក្ដីដូច្នេះសព្វគ្រប់ហើយ សូមលោកតាំងចិត្តក្លៀវក្លាហានឲ្យមាំមួនដូចសសរខឿនកុំភោតញញើត កុំរន្ធត់តក់ស្លុត សព្វបើគ្រាន់តែឮសំឡេងកង់រំពងប៉ុណ្ណោះ ព្រោះថា ៖

១០៨ – មុនដំបូង ខ្ញុំមើលទៅដឹងថា " ស្គរនេះ ពេញបរិបូណ៌ដោយសាច់និងខ្លាញ់ " លុះបួលទៅខាងក្នុងហើយ មើលទៅឃើញមានសុទ្ធតែ " ស្បែក និងឈើ " ។ (មាឌត)

---

១ គំនូសពីកំណើត ឬគំគូសដែលពួកហិណ្ឌូគូសពង់ថ្ងាស ជា:គ្រឿងសំគាល់បុគ្គលប្រសើរ ឬនិកាយផ្សេងៗ ។

## សេចក្ដីថ្លែងការណ៍គណៈកម្មាធិការ

សមាគមមិត្តសាលាបាលី បានបង្កើតសាលាសមាគមនៅខេត្តក្រៅ សឹងមានចំនួនទឹងកាលបរិច្ឆេទព្រមទាំងនាមរបស់លោកជាក្រុមអភិបាល ដូចតទៅនេះ:

ស្រុកល្វាឯម - ខេត្តកណ្ដាល (៥-២-៥០)

លោក ទេព-ជឿន ជាលេខាធិការ; លោក គង់-កែវ អនុលេខាធិការ; លោក ហាក់-ឡោ ហេរញ្ញិក; លោក ព្រំ-នួន អនុហេរញ្ញិក; លោក ប៊ុន-ថាន់, ម៉ាង-នាង, សោម-ស, អ៊ុច-ឌុយ, ឯម-ញ៉ែម, ម៉ម-យ៉ែម, ជាទីប្រឹក្សា ៗ

ខេត្តកំពត (២០-៣-៥០)

លោក តាប-ស៊ុម ជាលេខាធិការ; លោក ហង់-សារិន អនុលេខាធិការ; លោក ហុង-តាក់ឈាង ហេរញ្ញិក; លោក ឃុត-ឃៀម អនុហេរញ្ញិក; លោក ស៊ិន-ឈុន, ញិម-ស្រគុន, តាន់-កៅគា, អ៊ុង-ធុម ជាទីប្រឹក្សា ៗ

ស្រុកស៊ីសុផុន - ខេត្តបាត់ដំបង (៣-៥-៥០)

លោក ជា-ញាណ ជាលេខាធិការ; លោក ផោក-យិប អនុលេខាធិការ; លោកស៊ឹង-ផោក ហេរញ្ញិក; លោក ឈុំ-ព៉ន អនុហេរញ្ញិក; ព្រះគ្រូសោភ័ណវិមល កង-ឌុក, លោកសារ, លោកម៉ឹយ ជាទីប្រឹក្សា ៗ

ខេត្តព្រៃវែង (៣-៦-៥០)

លោក ប៉ុន-ម៉ៃ ជាលេខាធិការ; លោក នៅ-ជៀប អនុលេខាធិការ; លោក គួច-ថៃម ហេរញ្ញិក; លោក យក់-សាមឿន អនុហេរញ្ញិក; លោក សម-ជ័យ, សួស-យី, ធឹម-សាន, សួស-ប៊ុត, ឌី-ប៊ិន ជាទីប្រឹក្សា ។

ខេត្តពោធិ៍សាត់ (១២-៧-៥០)

លោក ព៉-បួន ជាលេខាធិការ; លោក ម៉ែន-ជិន អនុលេខាធិការ; លោក ពៀ៉ម-ទុយ ហេរញ្ញិក; លោក ជូ-ហ៊ឹម អនុហេរញ្ញិក; ព្រះតេជព្រះគុណ សួស-សួន, ប៉ាង-ទិម, ពៅ, សុទ្ធ, ពៅ-ងិន, អ៊ុង-ឈិត, កែ-ឌុល និងលោកសួន-ស៊ុន, យង់-សួត ជាទីប្រឹក្សា ។

ស្រុកមង្គលបុរី-បាត់ដំបង (៧-៧-៥០)

លោក ព៉-ប៊ុនឡេង ជាលេខាធិការ និងហេរញ្ញិក, លោកច័ន្ទ-ស៊ុត អនុលេខាធិការ, លោកព្រីង-សាឃន ទីប្រឹក្សា ។

ស្រុកជីក្រែង-សៀមរាប (២១-៩-៥០)

លោក កែប-អាង ជាលេខាធិការ; តាន់-ហ៊ារ អនុលេខាធិការ; អាំង-ហ៊ត ហេរញ្ញិក, តាំង-ហ៊ត អនុហេរញ្ញិក; ព្រះតេជព្រះគុណ ទិត-សាំង, ព្រះមហា ប៉ា-ធុម និងលោក អាំង-អ៊ាង, ស៊ុន-សន, ន-ប៊ុនគ្រួយ, អាំង-គិមវង់, គិម-ហួន ជាទីប្រឹក្សា ។

IMPRIMERIE ROYALE